វេទិកាពលរដ្ឋ
PEOPLE FORUM
ពលរដ្ឋខ្លាំង ជាតិខ្លាំង
STRONG PEOPLE STRONG NATION


សហរដ្ឋអាមេរិក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

# សេចក្ដីថ្លែងការណ៍

## គ.ជ.ប. បង្ហាញស្មារតីជាស្ថាប័នអធម្មនុញ្ញភាព

ដោយពិនិត្យពិចារណាលើសេចក្ដីថ្លែងការណ៍របស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(**គ.ជ.ប.**) នៅថ្ងៃទី១៣ មិថុនា ឆ្នាំ២០២២ ព្រមានចាត់វិធានការផ្លូវច្បាប់ លើគណបក្សនយោបាយ និង អ្នកទាំងឡាយណា ដែលរិះគន់ការបោះឆ្នោតឃុំ/សង្កាត់

**វេទិកាពលរដ្ឋ** យល់ឃើញថា **គ.ជ.ប.** ខ្លួនឯង ធ្វើឲ្យបាត់សេចក្ដីថ្លៃថ្នូរ និង តម្លៃជាស្ថាប័នអនុវត្តន៍ច្បាប់បោះឆ្នោតដោយខ្លួនឯង ហើយសូមកុំមានពុតត្បុតនយោបាយបន្ទោសអ្នកដទៃ ពីព្រោះ ៖

១. **គ.ជ.ប.** បានប្រកាសព្រមានធ្វើទុក្ខបុកម្នេញលើអ្នកគ្រប់គ្នាណា ដែលលើកហេតុផលចង់បានយុត្តិធម៌ក្នុងការបោះឆ្នោតទៅវិញ។ ជាក់ស្ដែង គឺស្ថាប័នថ្នាក់ក្រោមរបស់ **គ.ជ.ប.** ដែលបានរំលោភលើខ្លឹមសាររដ្ឋធម្មនុញ្ញ ដូចជា បិទទ្វារការិយាល័យរាប់សន្លឹកឆ្នោត មិនឲ្យប្រជាពលរដ្ឋម្ចាស់ឆ្នោតបានឃើញនិងដឹងឮ។ ការមិនបង្ហាញតម្លាដល់ប្រជាពលរដ្ឋ គឺជាអំពើបំពានសិទ្ធិពលរដ្ឋ ឬ បំពានខ្លឹមសារនៃរដ្ឋធម្មនុញ្ញរបស់ប្រទេសជាតិ។

២. **គ.ជ.ប.** បានចេញសេចក្ដីថ្លែងការណ៍ព្រមានប្រើវិធានការផ្លូវច្បាប់ បំពានលើក្រុមអ្នករិះគន់បែបនេះ គឺ*តែប៉ុន្មានម៉ោង*ក្រោយការថ្លែងមិនសប្បាយចិត្តរបស់លោក **ហ៊ុន សែន** ប៉ុណ្ណោះ។ **គ.ជ.ប.** ***ពុំមានលក្ខណៈសម្បត្តិ ជាស្ថាប័នធម្មនុញ្ញភាពឡើយ*** ប៉ុន្តែ ស័ក្តិសមជា***អង្គភាពបំពេញគោលដៅនយោបាយអំណាច*** របស់លោក **ហ៊ុន សែន** ក្នុងផែនការប្លន់លទ្ធផលបោះឆ្នោត។

**វេទិកាពលរដ្ឋ** ពិនិត្យឃើញថា អ្នកដែលត្រូវប្រឈមវិធានការផ្លូវច្បាប់ មុនអ្នកណាៗទាំងអស់ គឺ ***ប្រធាន គ.ជ.ប.*** ហើយ ស្ថាប័នដែលត្រូវកែទម្រង់ជាបឋមនិងជាបន្ទាន់ ក៏គឺ **គ.ជ.ប.**ដែរ។

**វេទិកាពលរដ្ឋ** មើលឃើញថា មានជម្រើសតែមួយគត់ ដើម្បីទប់ទល់នឹងស្ថាប័នអធម្មនុញ្ញភាព ដូច **គ.ជ.ប.** សព្វថ្ងៃ គឺ គណបក្សនយោបាយក្រៅរដ្ឋាភិបាល គួរ**ឆាប់ប្រញាប់រកវិធីបង្កើតគោលការណ៍រួម ក្នុងចលនានយោបាយរួបរួមជាកម្លាំងធំ**។

**ប្រធាន វេទិកាពលរដ្ឋ**

**គឹម សុខ**


Address: 58 Poplar Street, Plains PA 18 705, USA